# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៤ សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវ ធាតុភាពមិនប្រក្រតីនាំមនុស្សទៅបរទេសនៅក្រសួងទេសចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១.–**

បង្កើតគណៈកម្មការអន្តរក្រសួងស្រាវជ្រាវធាតុភាពមិនប្រក្រតីនាំមនុស្សទៅសហរដ្ឋអាមេរិក នៅក្រសួងទេសចរណ៍ ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ស៊ាន វិសុទ្ធ | សមាជិកអចិន្ត្រៃយ៍នៃអង្គភាពប្រឆាំងរាល់សកម្មភាពអំពើពុករលួយ | ប្រធាន |
| ២- ឯកឧត្តម យូ ស៊ិនឡុង | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម រស់ សូផាន់ | អគ្គនាយក នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | សមាជិក |
| ៤- ឯកឧត្តម អ៊ុំ ហុកលីម | អគ្គាធិការ នៃក្រសួងកសិកម្ម | សមាជិក |
| ៥- ឧត្តមសេនីយត្រី យ៉ុន ឈុនី | ប្រធាននាយកដ្ឋានជនបរទេស ក្រសួងមហាផ្ទៃ | សមាជិក |
| ៦- លោក សៅ សារឿន | អធិការ នៃក្រសួងទេសចរណ៍ | សមាជិក |
| ៧- លោក ឆាយ សុខន | ប្រធាននាយកដ្ឋានច្បាប់ និង កុងស៊ុលក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |

www.pheakdeylaw.com

ប្រការ ២.-

គណៈកម្មការនេះមានភារកិច្ច :

-ធ្វើការស្រាវជ្រាវបាត់ភាពមិនប្រក្រតី ក្នុងគណៈប្រតិភូទៅសហរដ្ឋអាមេរិក ដោយប្រើប្រាស់លិខិតឆ្លងដែនផ្លូវការ និងយកឈ្មោះក្របខ័ណ្ឌមន្ត្រីក្រសួងទេសចរណ៍ នៃគណៈប្រតិភូដែលដឹកនាំដោយឯកឧត្តម វ៉េង សាខុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍

-ធ្វើការទំនាក់ទំនង និងសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីប្រមូលផ្តុំលិខិតឯកសារ និងពត៌មាននានាជុំវិញករណីខាងលើ

-បូកសរុបលទ្ធផលនិងវាយតម្លៃអោយបានច្បាស់លាស់រួចរាយការណ៍ជូនរាជរដ្ឋាភិបាលដើម្បីមានវិធានការណ៍ជាក់ស្តែង ។

ប្រការ ៣.-

សមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រាររបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសំរួលការងារ ។

ប្រការ ៤.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ នឹងសេចក្តីសំរេចនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម និងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០១



ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com